ខុមហ្វ្រែល COMFREL

និកហ្វិច NICFEC

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពី
# សកម្មភាព និងគោលបំណង «អ្វីទៅជាបន្ទប់ស្ថានការណ៍?»

ភ្នំពេញ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧

សូមជំរាបជូនជាព័ត៌មានថា «បន្ទប់ស្ថានការណ៍» គឺជាវេទិកាអព្យាក្រឹត្យឥតលំអៀង ដែលរៀបចំ និងចាត់ចែងដោយគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា «ខុមហ្វ្រែល» និងគណៈកម្មាធិការអព្យាក្រឹត្យ និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា ហៅកាត់ថា«និកហ្វិច» ដែលមានការចូលរួមដោយស្ម័គ្រចិត្តពីអង្គការ និងសមាគម ចំនួន៤០ ទៀត ក្នុងគោលបំណងសម្របសម្រួល និងសហការរួមគ្នាដើម្បី៖

- ប្រមូលផ្ដុំធនធាន ដើម្បីបង្កើនសមត្ថភាព និងការរួមចំណែកសហការជាមូលនិធិ ឬគាំទ្រ ដើម្បីដំណើរការផែនការដាក់ពង្រាយអ្នកសង្កេតការណ៍ក្នុងស្រុកនៅថ្ងៃបោះឆ្នោត
- ចែករំលែក និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ទាក់ទងការបោះឆ្នោត
- ធ្វើការវាយតម្លៃ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត ដោយផ្អែកលើបទដ្ឋានច្បាប់ជាតិ និងអន្តរជាតិក្នុងអំឡុងពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។

ខុមហ្វ្រែល និងនិកហ្វិច បានដាក់ពង្រាយអ្នកសង្កេតការណ៍ដែលមានការទទួលស្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។

ក្រោយពីការបោះឆ្នោតត្រូវបានបញ្ចប់រួចរាល់ សកម្មភាពវេទិកាបន្ទប់ស្ថានការណ៍ក៏ត្រូវបានប្រកាសបញ្ចប់នៅក្នុងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៧ ក្នុងវេទិកាសាធារណៈ ស្ដីពីការវាយតំលៃចុងក្រោយលើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ នៅស្នាក់ការកណ្ដាលខុមហ្វ្រែល នៅចំពោះមុខអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ។

***ព័ត៌មានបន្ថែមសូមទាក់ទង៖***


| | | |
|---|---|---|
| ១. លោក គឹម ឈន | អ្នកសម្របសម្រួលជាន់ខ្ពស់នៃកម្មវិធីខុមហ្វ្រែល | ០១២ ៩៤២ ០១៩ |
| ២. លោក សំ គន្ធាមី | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៨២២ ២៧៣ |